# សេចក្ដីប្រកាសព័ត៌មាន

## ស្ដីពី

## « ការប្រកាសសាលដីកាសាលាឧទ្ធរណ៍ លើបុគ្គលិក និងអតីតបុគ្គលិក សមាគមអាដហុក នៅវេលាម៉ោង៨ព្រឹក ថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០២២ »

សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា ហៅកាត់ថា "**អាដហុក**" មានកិត្តិយសសូមជូនដំណឹងដល់សាធារណៈជន អង្គការសង្គមស៊ីវិលជាតិ អន្តរជាតិ ស្ថានទូតអន្តរជាតិ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិទាំងអស់ជ្រាបថា នៅវេលាម៉ោង ៨:០០ ព្រឹកថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០២២ ខាងមុខនេះ សាលាឧទ្ធរណ៍ នឹងប្រកាសសាលដីកាសម្រេចសេចក្ដីលើ សាលក្រមព្រហ្មទណ្ឌលេខ ៧៣០ ក្រវ"ថ" ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានសម្រេចផ្ដន្ទាទោសបុគ្គលិកសមាគមអាដហុកចំនួន ០៣ (បី) រូប រួមមានលោក **នី សុខា** លោក **យី សុខសាន្ត** និងលោកស្រី **លឹម មុន្នី** និងអតីតបុគ្គលិកអាដហុកចំនួន ០២ (ពីរ) រូបទៀតគឺលោក **ណៃ វង់ដា** និងលោក **នី ចរិយា** ដាក់ពន្ធនាគារ ម្នាក់ៗកំណត់០៥ឆ្នាំ ដោយត្រូវអនុវត្តក្នុងពន្ធនាគាររយៈពេល១៤ (ដប់បួន) ខែ និងសល់ប៉ុន្មានឮរ ពីបទ "**សូកប៉ាន់សាក្សី**" ត្រូវបានចាប់ខ្លួនដោយអង្គភាពប្រឆាំងអំពើពុករលួយកាលពីថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០១៦ តាមមាត្រា ៥៤៨ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ហើយត្រូវបានបញ្ជូនទៅឃុំខ្លួននៅពន្ធនាគារនៅថ្ងៃទី ០១ ខែឧសភា ឆ្នាំ២០១៦ រហូតដល់ថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០១៧ ហើយត្រូវបានអ្នកទាំង ៥ រូបប្ដឹងទៅសាលាឧទ្ធរណ៍ កាលពីចុងឆ្នាំ២០១៨ ដើម្បីរកយុត្តិធម៌ និងផ្ដល់នូវកិត្តិយសដល់ពួកគាត់វិញ ។

**សូមបញ្ជាក់ថា** កាលពីរសៀលថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២២ សាលាឧទ្ធរណ៍ភ្នំពេញ បានបើកសវនាការជំនុំជំរះលើបណ្ដឹងឧទ្ធរណ៍របស់អ្នកទាំងប្រាំខាងលើ ដោយមិនទាន់បានប្រកាសសាលដីកានៅឡើយ និងលោកចៅក្រមប្រឹក្សាបានសម្រេចលើកពេលប្រកាសសាលដីកាមកវេលាម៉ោង៨ ថ្ងៃទី២៣ ខែឧសភា នេះ ។

ដូច្នេះ យើងខ្ញុំសូមគោរពអញ្ជើញសាធារណៈជន អង្គការសង្គមស៊ីវិលជាតិ អន្តរជាតិ តំណាងស្ថានទូត អ្នកសារព័ត៌មានជាតិ និងអន្តរជាតិទាំងអស់ ចូលរួមតាមដានកុំបីខាន ៕

សូមអរគុណ!

**សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងៈ**

**លោក ភិន សាវ៉ៃ** ៖ (855) 68 831 666